# អភិបូជាទិវាគ្រួសារសម្រាប់មណ្ឌលសកម្មភាពតាកែវ
# នៅព្រះសហគមន៍សន្តីម៉ារីញញឹម ចំការឡៀង
# តាកែវ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២២
# “ស្រឡាញ់ដើម្បីឆ្លងគ្រប់ទុក្ខលំបាក”

**អត្ថបទទី១៖ សាម៉ូអែល ទី២ ៥,១-៣**

ទូលបង្គំទាំងអស់គ្នាក៏ជាសាច់សាលោហិតរបស់ព្រះករុណា។ ២សម ៥,១

**អត្ថបទទី១៖ កូឡូស ១,១២-២០**

ព្រះអង្គជាសិរសានៃព្រះកាយរបស់ព្រះអង្គ។ កូឡ ១,១៨

**ដំណឹងល្អ៖ លូកា ២៣,៣៥-៤៣**

ឯងមិនកោតខ្លាចព្រះជាម្ចាស់ទេឬ? លក ២៣,៤០

បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះ ជាថ្ងៃពិសេសបំផុតសម្រាប់ព្រះសហគមន៍នៅក្នុងពិភពលោក ដែលយើងគោរពព្រះយេស៊ូជាព្រះមហាក្សត្រនៃផែនដី។ ថ្ងៃនេះ ជាថ្ងៃពិសេសបំផុតដែរសម្រាប់យើងដែលជាគ្រីស្តបរិស័ទ នៅក្នុងមណ្ឌលសកម្មភាពតាកែវ។ យើងប្រមូលបងប្អូនទាំងអស់ ជាគ្រួសារ ជាគ្រីស្តបរិស័ទ ដើម្បីលើកតម្កើងទាំងព្រះយេស៊ូ ទាំងគ្រួសារដ៏វិសុទ្ធ ដើម្បីទទួលកម្លាំងថ្មីសម្រាប់ជីវិតរបស់យើង ដែលជាគ្រីស្តបរិស័ទកំពុងធ្វើដំណើរនៅលើផែនដីនេះ។

អំបាញ់មិញ នៅពេលខ្ញុំដើរខ្ញុំឃើញគ្រួសាររបស់យើងមានគ្រប់លក្ខខណ្ឌ មានប្ដីប្រពន្ធមានកូន មានគ្រួសារខ្លះមេម៉ាយ។ បងប្អូនជាទីស្រឡាញ់ អ្វីដែលសំខាន់ថ្ងៃនេះគឺឲ្យយើងយល់ថា យើងជាគ្រួសារនៅក្នុងជីវិតរបស់យើងផ្ទាល់។ មានន័យថា យើងមានប្ដី យើងមានប្រពន្ធ យើងមានកូន មានខ្លះពិតមែនយើងជាមេម៉ាយ មានខ្លះយើងបែកគ្នា មានខ្លះមានទុក្ខលំបាក មានខ្លះមានអំណរ

សប្បាយ មានខ្លះកំពុងគិតអំពីអនាគត ជាពិសេសសម្រាប់មេៗកាយរិទ្ធិ កំពុងគិតអំពីអនាគត **តើយើងបង្កើតគ្រួសារយ៉ាងដូចម្ដេច?**

អ្វីដែលយើងត្រូវការនឹកឃើញ ថ្ងៃនេះយើងមានគ្រួសាររបស់យើងផ្ទាល់ ប៉ុន្តែយើងទាំងអស់គ្នាជាគ្រួសារមួយដែរ។ នេះជាការអស្ចារ្យ នៅពេលដែលយើងជួបជុំគ្នាជាគ្រីស្តបរិស័ទ នៅក្នុងមណ្ឌលសកម្មភាពតាកែវដែលយើងមានប្រាំបីកន្លែង យើងដឹងថាមិនមែនតែគ្រួសារបង្កើតរបស់យើងទេ ដែលយើងនឹកឃើញ។ ថ្ងៃនេះ យើងនឹកឃើញដល់ព្រះសហគមន៍យើង ដែលជាមហាគ្រួសារមួយ ដែលជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់។ ថ្ងៃនេះដែលយើងបានរៀបចំផ្កាយ៉ាងស្អាតបំផុត យើងបានជូនបងប្អូនទាំងអស់ ដើម្បីឲ្យផ្កានេះណែនាំឲ្យយើងមើលឃើញសេចក្ដីស្រឡាញ់ដែលព្រះជាម្ចាស់មានសម្រាប់យើង។ មើលឃើញជីវិតដែលយើងបានទទួលជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ ជាពិសេសថ្ងៃនេះយើងមានកូនក្មេងប្រាំនាក់ ដែលនឹងទទួលអគ្គសញ្ញាជ្រមុជទឹក។ ថ្ងៃនេះយើងមើលឃើញជីវិតដ៏អស្ចារ្យដែលព្រះជាម្ចាស់បានរៀបចំ ស្អាតដូចផ្កាដែលយើងមាននៅពេលហ្នឹង។

ថ្ងៃនេះ យើងមើលព្រះយេស៊ូ យើងមើលព្រះមាតា យើងមើលសន្តយ៉ូសែប ដែលជាគ្រួសារដ៏វិសុទ្ធ។ គ្រួសារដ៏វិសុទ្ធ ដែលកំពុងសម្លឹងមើលយើង ប្រសិនបើយើងងើបមុខរបស់យើង នៅពេលយើងមើលគ្រួសារដ៏វិសុទ្ធនេះ ដែលមានដើមត្នោតអមសងខាង យើងមើលឃើញជីវិតដ៏ពិសេសដែលព្រះជាម្ចាស់បានរៀបចំសម្រាប់យើង។ ទោះបីជិវិតគ្រួសាររបស់យើង ជួបទុក្ខលំបាក ជួបបញ្ហាខ្លះៗ ប៉ុន្តែយើងដឹងថាយើងមានគ្រួសារដ៏វិសុទ្ធការពារថែរក្សាយើងជានិច្ច យើងមានព្រះនាងម៉ារី សន្តយ៉ូសែប ព្រះយេស៊ូដែលគង់នៅជាមួយយើងជានិច្ច។ យើងដឹងថា នៅក្នុងគ្រប់កាលៈទេសៈនៃជីវិតរបស់យើង យើងអាចធ្វើដំណើរទៅមុខដោយសារយើងមានមហាគ្រួសារមួយដ៏ពិសេស ដែលចេះស្រឡាញ់ ដែលចេះស្វាគមន៍ ដែលចេះអញ្ជើញ ដែលចេះស្ដាប់គ្នាទៅវិញទៅមក ដែលចេះអធិដ្ឋាន ដែលចេះសម្រុះសម្រួលបញ្ហាដែលយើងជួបនៅក្នុងជីវិតប្រចាំ។ ដូច្នេះ ថ្ងៃនេះខ្ញុំចង់អញ្ជើញឲ្យបងប្អូនសម្លឹងមើល ជាពិសេសព្រះនាងម៉ារី។ ព្រះនាងម៉ារី ដែលជាម្ដាយរបស់ព្រះយេស៊ូ ព្រះនាងម៉ារីដែលជាម្ដាយរបស់យើង ដែលជាម្ដាយរបស់ព្រះសហគមន៍របស់យើង។ ដូច្នេះ ពេលយើងមើលឃើញព្រះនាងម៉ារី យើងត្រូវតែមើលឃើញរបៀបដែលយើងចង់បង្កើតគ្រួសាររបស់យើង គ្រួសារបង្កើតនិងគ្រួសារនៅក្នុងព្រះសហគមន៍។ គ្រួសារបង្កើតនិងគ្រួសារនៅក្នុងព្រះសហគមន៍ ដែលមើលព្រះនាងម៉ារីះ

**ទីមួយ ព្រះនាងម៉ារីស្តាប់**ព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅពេលទេវទូតកាព្រីអែល បានប្រាប់ដំណឹងដល់ព្រះនាងម៉ារីធ្វើជាមាតារបស់ព្រះជាម្ចាស់ ព្រះនាងម៉ារីបានស្តាប់ព្រះបន្ទូលនេះ។ ព្រះនាងម៉ារី បានយកចិត្តទុកដាក់ធ្វើតាមព្រះបន្ទូលនេះ ព្រះនាងម៉ារីស្តាប់ព្រះកុមារយេស៊ូ ព្រះនាងម៉ារីស្តាប់ប្តីផ្ទាល់ខ្លួន។ ខ្ញុំគិតថា ដើម្បីឲ្យគ្រួសាររបស់យើងរកឃើញសេចក្តីសុខ យើងជាប្តីប្រពន្ធ យើងជាឪពុកម្តាយ យើងជាកូន យើងត្រូវតែចេះស្តាប់គ្នាទៅវិញទៅមក។ ប្រហែលមានគ្រួសារខ្លះអត់ដែលយកពេលដើម្បីនិយាយគ្នា ដើម្បីចែកយោបល់គ្នា។ ដូច្នេះ ខ្ញុំសង្ឃឹមយូរៗម្តងយើងត្រូវការអង្គុយដើម្បីនិយាយគ្នា អំពីជីវិត អំពីកូន អំពីអនាគត អំពីបញ្ហាដែលយើងមាន។ នៅពេលកូនរបស់យើងមកពីសាលាវិញ ត្រូវការស្តាប់កូនដែរ ដូចនៅពេលសម័យកូវីដឪពុកម្តាយនៅសាលាមត្តេយ្យ សាលាបឋមសិក្សារបស់យើង ឪពុកម្តាយមួយអាទិត្យម្តងបានទៅដល់សាលាដើម្បីទទួលមេរៀន។ ក្រោយមក ពេលទៅដល់ផ្ទះវិញឪពុកម្តាយបានរកពេលបង្រៀនកូន ជួបជាមួយកូន ដើម្បីយកចិត្តទុកដាក់ជាមួយកូន។ ពេលផុតកូវីដហើយ ប្រហែលយើងលែងនឹកឃើញដោយសារយើងរវល់ ពេលកូនរបស់យើងយំយើងឲ្យទូរស័ព្ទទៅកូនលេង។ និងក្រោយមកកូនបានលេងទូរស័ព្ទ ពេលកូនខឹងបោះចោលទូរស័ព្ទថ្លៃៗ ធ្វើឱ្យយើងបាត់បង់លុយដែលពិបាករក។ ប៉ុន្តែ ប្រសិនបើយើងយកពេលដើម្បីនិយាយខ្លះៗ ដើម្បីស្តាប់កូន កូនបានរៀនមេរៀនអ្វី បទចម្រៀងបទអ្វី ពាក្យកំណាព្យអ្វី បានគូសរូបអ្វី នោះជីវិតនៅក្នុងគ្រួសារបានរីកចម្រើនបន្តិចម្តងៗ ដូចព្រះនាងម៉ារីបានចេះស្តាប់។

**ទីពីរ** ពេលយើងមើលព្រះនាងម៉ារីដែលកំពុងសម្លឹងមើលព្រះកុមារយេស៊ូ **ព្រះនាងម៉ារីកំពុងយកចិត្តទុកដាក់**នឹងកូនដែលទើបតែកើតថ្មីៗ។ យើងដឹងហើយ នៅពេលម៉ែមានកូនកើត គាត់យកចិត្តទុកដាក់ថែរក្សា។ ដូច្នេះ ការយកចិត្តទុកដាក់តាមរបៀបព្រះនាងម៉ារី ជាបទពិសោធន៍ដែលយើងមានពេលនៅធ្វើជាម្តាយ។ គ្រប់ពេលវេលាយកចិត្តទុកដាក់ជាមួយកូន យកចិត្តទុកដាក់ជាមួយប្តី ដើម្បីឲ្យគ្រួសាររកឃើញសេចក្តីសុខ។ យកចិត្តទុកដាក់ និងតស៊ូច្រើនជាងគេគឺម៉ែ តស៊ូនៅក្នុងការពិបាក តស៊ូនៅពេលខ្វះលុយ តស៊ូពេលកូនៗឈឺ តស៊ូពេលកូនមានបញ្ហា តស៊ូពេលប្តីមានរឿង ម្តាយតស៊ូច្រើន ប៉ុន្តែក៏យកចិត្តទុកដាក់ច្រើនដែរ។ សព្វថ្ងៃ ខ្ញុំចាប់អារម្មណ៍ពេលកូនឈឺគឺប្តីដែលមើលកូនឈឺ ដូច្នេះប្រហែលប្តីយកចិត្តទុកដាក់ជាមួយកូនច្រើនដែរ។ សម័យមុន ម៉ែធ្វើម្ហូប ម៉ែសំអាតផ្ទះ ម៉ែបោកខោអាវ ម៉ែចិញ្ចឹមកូន... ឥលូវនេះប្តីបានជួយខ្លះៗដែរ ដូចជាជួយលាងចាន ជួយបោកខោអាវ ជួយបោសសំរាម...។ ក្រោយមកគ្រួសារយើងសុខសាន្ត ដោយសារយកចិត្តទុកដាក់ មិនមែនតែម៉ែយកចិត្តទុកដាក់ គឺឪពុកយកចិត្តទុកដាក់ដែរ។ ប៉ុន្តែ យើងក៏ត្រូវបង្រៀនកូនដែរ ដោយសារកូនរបស់យើងយូរៗខ្ជិលណាស់ ណែនាំឲ្យកូនចេះបម្រើ ចេះជួយ។ ឪពុកខ្ញុំធ្លាប់និយាយពេលខ្ញុំនៅក្មេងថា កូនជាអំណោយទានរបស់ព្រះជាម្ចាស់ដើម្បីបម្រើឪពុកម្តាយ។ ដូច្នេះ

នេះជាពេលវេលាមួយដើម្បីឲ្យយើងទាំងអស់គ្នា រៀនយកចិត្តទុកដាក់នឹងគ្នាទៅវិញទៅមក ទាំងកូនយកចិត្តទុកដាក់ជាមួយឪពុកម្តាយ ទាំងឪពុកម្តាយយកចិត្តទុកដាក់គ្នាទៅវិញទៅមក និងជាមួយលោកតាលោកយាយដែរ។

**ទីបី** ពេលយើងមើលព្រះនាងម៉ារី **ព្រះនាងម៉ារីស្រឡាញ់ ប៉ុន្តែតើស្រឡាញ់មានន័យដូចម្តេច? តើស្រឡាញ់មានន័យថា យើងស្រឡាញ់នៅពេលយើងសប្បាយចិត្តតែប៉ុណ្ណឹង ឬយើងចេះស្រឡាញ់គ្នានៅក្នុងគ្រប់កាលៈទេសៈ?** ស្រឡាញ់មានន័យថាយើងចេះស្រឡាញ់នៅក្នុងគ្រប់កាលៈទេសៈនៅក្នុងជីវិតរបស់យើង សេចក្តីស្រឡាញ់មិនមែនមានតែនៅពេលយើងសប្បាយចិត្ត។ បងប្អូនដែលបានទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍នៅក្នុងព្រះសហគមន៍ យើងបានប្រកាសពាក្យសន្យាថា "**បងសូមសន្យាថាស្រឡាញ់អូនអស់មួយជីវិតរបស់បង ទាំងគ្រាសប្បាយ ទាំងគ្រាអាសន្ន...**"។ បងប្អូនជាប្តីប្រពន្ធ ជាឪពុកម្តាយយូរឆ្នាំហើយ យើងដឹងយើងមានអំណរសប្បាយ ប៉ុន្តែយើងមានទុក្ខលំបាក យើងមានសេចក្តីសង្ឃឹម ប៉ុន្តែយើងមានរឿងដែលណែនាំឲ្យយើងមានគ្រោះថ្នាក់ខ្លះៗ។ ប៉ុន្តែ សេចក្តីស្រឡាញ់អាចឆ្លងផុតគ្រប់បញ្ហា ម្តាយស្រឡាញ់កូនរហូត ទោះបីកូនដែលខូចក៏ដោយយើងនៅតែស្រឡាញ់កូន។ នេះជារបៀបដែលព្រះនាងម៉ារីបានបង្រៀនយើង "**ចេះស្រឡាញ់ដើម្បីឆ្លងគ្រប់ទុក្ខលំបាក**"។ យើងមើលព្រះនាងម៉ារី នៅពេលព្រះកុមារយេស៊ូបាត់បីថ្ងៃ ដោយសារកូនចូលវិហារដើម្បីបង្រៀនដល់ធម្មាចារ្យ។ ដូច្នេះ ម៉ែគាត់ភ័យរត់តាមរកកូនបីថ្ងៃបីយប់ ពេលរកឃើញគាត់មិនវៃ មិនស្តីឲ្យកូនឡើយ គាត់គ្រាន់តែនិយាយថា កូនអើយម៉ែភ័យណាស់ ម៉ែព្រួយបារម្ភណាស់ ព្រោះអត់ដឹងថាកូនទៅណា។ ព្រះនាងម៉ារីបានធ្វើដំណើរជាមួយព្រះយេស៊ូរហូតដល់ឈើឆ្កាង ដែលព្រះយេស៊ូបានសោយទិវង្គត។

**ទីបួន** មហាកំពូលសម្រាប់ជីវិតរបស់យើងជាគ្រីស្តបរិស័ទ **គឺព្រះនាងម៉ារីបានអធិដ្ឋានជានិច្ច**។ អធិដ្ឋានជាកម្លាំងមួយយ៉ាងពិសេស ដោយសារពេលយើងអធិដ្ឋានយើងដឹងថា យើងរកឃើញកម្លាំង។ ដោយសារ យើងជាប់ជាមួយព្រះជាម្ចាស់ ម្នាក់ឯងយើងដើរមិនបានទេ ប៉ុន្តែយើងនៅជាមួយព្រះជាម្ចាស់យើងធ្វើដំណើរទៅមុខបាន។ ជាមួយព្រះជាម្ចាស់នៅក្នុងព្រះសហគមន៍ យើងធ្វើដំណើរទៅមុខបាន យើងរកឃើញការលើកទឹកចិត្តនៅក្នុងព្រះសហគមន៍។ ថ្ងៃនេះ យើងមានយាយៗច្រើនមកពីសន្តប៉ូល ខ្ញុំបាននឹកឃើញថា យាយៗនៅតាមផ្ទះក៏ឯកោដែរ អត់សូវមានអ្នកនិយាយគ្នា អត់សូវមានអ្នកណាលើកទឹកចិត្ត។ ដូច្នេះ ពេលយើងចូលវិហារម្តងៗ យើងមានកម្លាំងដែរ យើងរកឃើញគ្រួសារមួយដែលចេះលើកទឹកចិត្តគ្នាទៅវិញទៅមក។ ណែនាំឲ្យយើងយល់ថាយើងមានព្រះយេស៊ូ យើងមានបងប្អូន ដែលជាគ្រីស្តបរិស័ទ យើងធ្វើដំណើរជាមួយគ្នានៅក្នុង

សេចក្តីសុខ និងអំណរសប្បាយ។ ខ្ញុំជឿថា នេះជាអត្ថន័យដ៏ពិសេសនៃព្រះសហគមន៍របស់យើង ព្រះសហគមន៍របស់យើងណែនាំឲ្យយើងកក់ក្តៅ។ ថ្ងៃនេះ ខ្ញុំបានឃើញបងប្អូនគ្រីស្តបរិស័ទមួយចំនួន គ្រួសារមួយចំនួនដែលមិនបានជួបពីយូរ ខ្ញុំសប្បាយចិត្តណាស់ ព្រះយេស៊ូក៏សប្បាយចិត្ត យើងជាមហាគ្រួសារតែមួយក៏សប្បាយចិត្តមែនទែន។ ដែលបានធ្វើដំណើរជាមួយគ្នា ដោយដឹងថាមួយរយៈកន្លងមកយើងអត់សូវចូលព្រះវិហារ។ ប៉ុន្តែ ឥលូវនេះយើងមកដើម្បីទទួលព្រះពរពីព្រះជាម្ចាស់ ដោយសារនៅក្នុងដួងចិត្តរបស់យើង យើងបានថែរក្សាជំនឿរបស់យើង ដែលបានទទួលពីថ្ងៃពិធីជ្រមុជទឹក។ យើងដឹងថា ជំនឿនេះមិនទៅណាទេ ដោយសារព្រះជាម្ចាស់គង់នៅជាមួយយើងជានិច្ច។

បងប្អូនជាទីស្រឡាញ់ ថ្ងៃនេះជាពេលវេលាមួយយ៉ាងពិសេស ដើម្បីអរព្រះគុណព្រះជាម្ចាស់ ដែលបានបង្កើតយើង ដែលបានប្រទានសេចក្តីស្រឡាញ់ឲ្យយើង ដែលបានណែនាំឲ្យយើងជាគ្រួសារតែមួយនៅក្នុងព្រះសហគមន៍ ដែលបានណែនាំឲ្យយើងមានកម្លាំងកាយកម្លាំងចិត្ត ដើម្បីឆ្លងគ្រប់ឧបសគ្គ។ ប៉ុន្តែ ដើម្បីទៅដល់ព្រះរាជ្យរបស់ព្រះជាម្ចាស់ ដោយសារថ្ងៃនេះនៅក្នុងគម្ពីរ យើងបានស្តាប់ព្រះយេស៊ូ ដែលមានព្រះបន្ទូលថា "**ខ្ញុំសូមប្រាប់ឲ្យអ្នកដឹងច្បាស់ថា ថ្ងៃនេះអ្នកបាននៅស្ថានបរមសុខជាមួយខ្ញុំ**"។ នេះជាព្រះបន្ទូលដែលយើងចង់ស្តាប់ ថ្ងៃនេះយើងនឹងនៅជាមួយព្រះជាម្ចាស់នៅស្ថានបរមសុខ។ ព្រះរាជ្យរបស់ព្រះជាម្ចាស់ចាប់ផ្តើមពីពេលនេះតទៅ ប៉ុន្តែលុះត្រាតែយើងយកចិត្តទុកដាក់ស្តាប់គ្នាទៅវិញទៅមក យកចិត្តទុកដាក់ថែរក្សាគ្នាទៅវិញទៅមក យកចិត្តទុកដាក់ស្រឡាញ់គ្នាទៅវិញទៅមក យកចិត្តទុកដាក់អធិដ្ឋានជាមួយព្រះជាម្ចាស់ និងអធិដ្ឋានសម្រាប់គ្នាទៅវិញទៅមក។ យើងនៅស្ងៀមស្ងាត់ ដោយអរព្រះគុណព្រះជាម្ចាស់ ដោយទូលអង្វរព្រះអង្គ សូមឲ្យព្រះអង្គគង់នៅជាមួយយើង ដើម្បីបំភ្លឺជីវិតរបស់យើងជាគ្រួសារ ដើម្បីឲ្យយើងរួមគ្នាពោរពេញដោយព្រះពរ ពោរពេញដោយសេចក្តីសង្ឃឹម។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ